មាត្រា៤ .-ចំណាយតាមការផ្ទេរនេះត្រូវផ្តល់ភាពពិតប្រាកដជាបន្ទាន់ភ្លាម ក្នុងច្បាប់ហិរញ្ញវត្ថុបន្ថែមក្រោយ ការបើកចំណាយពិតប្រាកដនេះត្រូវបានធានាគ្រប់ ។

មាត្រា៥ .-សហការីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ុង ហួត ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ៦១ អនក្រ.បក

## ស្តីពីការបង្កើតថវិកាសំរាប់ក្រុមប្រឹក្សាធម្មនុញ្ញ

## សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

****

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៥/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម /០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

-បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣

-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ជស.រកម /០១៩៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៨

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស.រកម /០៤៩៨ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ១៩៩៨

-បានឃើញអនុក្រឹត្យ លេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ។

-បានឃើញសេចក្តីសំរេច លេខ២២ សសរ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការដោះត្រាបបត្រិកានិងការប្រគល់ទីតាំងសំរាប់ធ្វើជាទីស្នាក់ការជូនក្រុមប្រឹក្សាធម្មនុញ្ញ ។

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**សំរេច**

**មាត្រា១** .-ដោយអនុលោមទៅតាមមាត្រា៤០ និងមាត្រា៤៣ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ត្រូវបានបង្កើតថវិកាមួយនៅក្នុងថវិការដ្ឋ ដែលមានលេខជំពូក២៥ សំរាប់ក្រុមប្រឹក្សាធម្មនុញ្ញ ប្រើប្រាស់ក្នុងការចំណាយចាំបាច់សំរាប់ការប្រព្រឹត្តិទៅរបស់ខ្លួន ។

**មាត្រា២** .-កិច្ចប្រតិបត្តិការនៃថវិការបស់ក្រុមប្រឹក្សាធម្មនុញ្ញនេះ ត្រូវអនុវត្តទៅតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងទៅតាមវិធានទាំងឡាយ មានជាអាទិ៍ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ តាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល ស្តីពីការគ្រប់គ្រងលើអ្នកគណនេយ្យសាធារណៈ ។

**មាត្រា៣** .-ត្រូវបានផ្ទេរឥណទានពីជំពូក ៥០ (ចំណាយផ្សេងៗ) មកអោយក្រុមប្រឹក្សាធម្មនុញ្ញ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ចំនួនទឹកប្រាក់សរុប ៨៣០លានរៀល ដែលរួមមានសំរាប់ជំពូក១០ (បៀវត្ស និងប្រាក់បំណាច់) ចំនួន ៣៣០ លានរៀល (បីរយសាមសិបលានរៀល) សំរាប់ជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈនិងផ្គត់ផ្គង់ទូទៅ) ចំនួន ៤៩០លានរៀល (បួនរយកៅសិបលានរៀល) និងសំរាប់ជំពូក៣១ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច និង វប្បធម៌) ចំនួន១០លានរៀល (ដប់លានរៀល) ។

**មាត្រា៤** .-ការបែងចែកឥណទានថវិកាផ្ទៃក្នុងជំពូកនីមួយៗ ទៅតាមប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា៥** .-បទបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យនេះ នឹងត្រូវបានធ្វើនិយ័តកម្ម នៅក្នុងច្បាប់ហិរញ្ញវត្ថុ នាពេលបន្ទាប់ៗខាងមុខ ។

**មាត្រា៦** .-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

**អ៊ឹង ហួត** **ហ៊ុន សែន**